**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
Ministry of Mines and Energy
លេខ: ០១៦៤.១៨.អរមថ.ប្រក

*រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែមេសា ឆ្នាំ២០១៥*

# ប្រកាស
# ស្តីពី
# ការបង្កើតក្រុមការងារកំណត់បុរេលក្ខណៈសម្បត្តិ និងបច្ចេកទេសពាក់ព័ន្ធនឹងការងារដាក់ដេញថ្លៃអាជីវកម្មរ៉ែខ្សាច់ របស់ក្រសួងរ៉ែ និងថាមពល

## រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែម សមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ១០៥.អនក្រ.ប.ក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសលេខ ៣៨១ សហវ.ប្រ.ក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសលេខ ០៦៣ រថ.គហ.ប្រក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃ និងប្រគល់កិច្ចសន្យា (គបវប-PEAC)
- បានឃើញប្រកាសលេខ ០៦៤ រថគហប្រក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៤ ស្តីពីការបង្កើតអង្គភាពលទ្ធកម្ម (អល-PU) របស់ក្រសួងរ៉ែ និងថាមពល
- យោងការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល

## សម្រេច

**ប្រការ១**–. បង្កើតក្រុមការងារកំណត់បុរេលក្ខណៈសម្បត្តិ និងបច្ចេកទេសពាក់ព័ន្ធនឹងការងារដាក់ដេញថ្លៃអាជីវកម្មរ៉ែខ្សាច់ របស់ក្រសួងរ៉ែ និងថាមពល ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-លោក | **ប៉េង ណារិទ្ធ** | អគ្គនាយករង | ប្រធាន |
| ២- លោក | **ឡៅ សុខុម** | ប្រធាននាយកដ្ឋាន | អនុប្រធាន |
| ៣- លោក | **ម៉ក់ សុគន្ធា** | ប្រធាននាយកដ្ឋាន | អនុប្រធាន |
| ៤-លោក | **ហ៊ីង ទន់** | អនុប្រធាននាយកដ្ឋាន | សមាជិក |

**ប្រការ២** – . ក្រុមការងារកំណត់បុរេលក្ខណៈសម្បត្តិ និងបច្ចេកទេសពាក់ព័ន្ធនឹងការងារដាក់ដេញថ្លៃអាជីវកម្មខ្សាច់ មានភារកិច្ចសម្របសម្រួលអនុវត្តនីតិវិធីលទ្ធកម្មជាមួយអង្គភាពលទ្ធកម្ម និងគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃ និងប្រគល់កិច្ចសន្យា (គបវប-PEAC) ដូចតទៅ៖

១-កំណត់បុរេលក្ខណៈសម្បត្តិសម្រាប់ក្រុមហ៊ុនដែលមានបំណងចូលប្រកួតប្រជែង ដេញថ្លៃពាក់ព័ន្ធនឹងអាជីវកម្មរ៉ែខ្សាច់ ដែលក្រសួងដាក់ដេញថ្លៃជាសាធារណៈ ដើម្បីប្រធានគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃ និងប្រគល់កិច្ចសន្យា (គបវប-PEAC) ពិនិត្យ និងសម្រេច

២- កណត់លក្ខណៈវិនិច្ឆ័យ ឆ្លងការវាយតម្លៃលក្ខណៈសម្បត្តិ របស់ក្រុមហ៊ុនដែលចូលរួមដេញថ្លៃជាសាធារណៈ ដើម្បីជូនប្រធានគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃ និងប្រគល់កិច្ចសន្យា (គបវប-PEAC) ពិនិត្យ និងសម្រេច

៣-ពិនិត្យ វាយតម្លៃលើផែនការអាជីវកម្ម លក្ខណៈបច្ចេកទេស និងធនធានហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់

៤- រៀបចំរបាយការណ៍លទ្ធផលវាយតម្លៃ ដាក់ជូនប្រធានគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃ និងប្រគល់កិច្ចសន្យា (គបវប-PEAC) ពិនិត្យ និងសម្រេច ក្នុងការប្រគល់កិច្ចសន្យា

៥-ទទួលភារកិច្ចផ្សេងៗទៀត តាមការចាត់តាំងរបស់ប្រធានគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃ និងប្រគល់កិច្ចសន្យា (គបវប-PEAC) ពិនិត្យ និងសម្រេច។

**ប្រការ៣** – . ប្រកាស សេចក្ដីសម្រេច និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤** – . ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី គ្រប់អគ្គនាយកដ្ឋានចំណុះក្រសួងរ៉ែ និងថាមពល អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពចំណុះក្រសួង និងសាមីខ្លួនត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

*កន្លែងទទួល៖*

- ទីស្ដីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- គ្រប់អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងរ៉ែ និងថាមពល
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**រដ្ឋមន្ត្រី**

**ស៊ុយ សែម**